## សុន្ទរកថារបស់លោក Russell Muir ប្រធានស្តីទីនៃសេវាប្រឹក្សាយោបល់
## តំបន់អាស៊ីប៉ាស៊ីហ្វិក សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
## សន្និសិទកំពូល មីក្រូហិរញ្ញវត្ថុ

១៩ សីហា ២០០៩ ភ្នំពេញ កម្ពុជា

**ឯកឧត្តម ជា ចាន់តូ ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា**

**ឯកឧត្តម Rafael Dochao Moreno ភារៈធារីស្តីទីនៃប្រតិភូសហគមន៍អឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ជំនួសមុខឱ្យសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ខ្ញុំសូមអបអរសាទរចំពោះអ្នកទាំងអស់ដែលបានរៀបចំសន្និសិទដ៏មានសារៈសំខាន់នេះឡើង ដើម្បីពិភាក្សាពីបញ្ហាប្រឈមនានានៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក។

ក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានដើរតួជាអ្នកគាំទ្រវិស័យមីក្រូហិរញ្ញវត្ថុដ៏ខ្លាំងក្លាមួយនៅកម្ពុជា។ នេះក៏ដោយសារតែជោគជ័យដែលអ្នកទាំងអស់សំរេចបាន នៅក្នុងការវិវត្តពីស្ថាប័នដែលពឹងផ្អែក លើម្ចាស់ជំនួយទៅជាស្ថាប័នដែលមាននិរន្តរភាព រួមជាមួយនឹងការប្តេជ្ញាចិត្តរបស់អ្នកទាំងអស់ លើគោលបំណងរួមរបស់យើង ក្នុងការពង្រីកសេវាហិរញ្ញវត្ថុទៅដល់ប្រជាជនក្រីក្រកម្ពុជារាប់លាននាក់ ដែលត្រូវការសេវាហិរញ្ញវត្ថុ។

ដូចដែល **ឯកឧត្តម** Rafael Dochao Moreno បានថ្លែងនៅក្នុងសុន្ទរកថារបស់ឯកឧត្តមពីខាងដើម ប្រជាជនក្រីក្រក៏ដូចជាមនុស្សគ្រប់គ្នាដែរ ត្រូវការសេវាហិរញ្ញវត្ថុដែលអាចរ៉ាប់រងបាន នូវតម្លាភាព និងមានការចាត់ចែងប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យគេអាចខ្ចីទុនដែលគេត្រូវការសំរាប់អាជីវកម្ម សន្សំប្រាក់ ទាញយកប្រាក់ចំនេញពីប្រាក់សន្សំរបស់គេធានារ៉ាប់រងលើពួកគេនិងទ្រព្យសម្បត្តិរបស់គេ និងផ្ទេរប្រាក់ក្នុងទំរង់ដែលអាចទុកចិត្តបាន។

ស្ថាប័នមីក្រូហិរញ្ញវត្ថុរបស់កម្ពុជាគឺជាស្ថាប័នដែលមានគំនិតផ្តួចផ្តើម និងបានក្លាយជាអ្នកនាំមុខគេលើពិភពលោកនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយបានផ្តាច់ខ្លួនពីជំនួយឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ ទៅជាស្ថាប័នដែលមាននិរន្តរភាពបែបពាណិជ្ជកម្ម។ ជាលទ្ធផលនៃការសំរេចចិត្តនេះ អ្នកអាចពង្រីកសេវាហិរញ្ញវត្ថុទៅដល់ប្រជាជនរាប់សែននាក់បន្ថែមទៀតនៅក្នុងរយៈពេលដ៏ខ្លី ជាពិសេសគឺមានអត្រាមិនសងប្រាក់ដ៏ទាប គឺតិចជាង ១% គិតមកដល់ ឆ្នាំ ២០០៨។ សូម្បីតែប្រាក់កំចីពិបាកទារក៏មានអត្រាទាបជាង ៤%ដែរ។ លោក អ្នកក៏បានសំរេចជោគជ័យលើផ្នែកសីលធម៌ និងតម្លាភាពផងដែរ ជាភស្តុតាងគឺពានរង្វាន់តម្លាភាពដែលវិស័យនេះតែងតែទទួលបានជារឿយៗ និងនៅតែឈរលើបេសកកម្មរបស់អ្នកក្នុងការជួយដល់ប្រជាជនក្រីក្រ ឱ្យកែលំអជីវភាព និងស្ថានភាពរស់នៅរបស់ពួកគេ។

ដើម្បីឱ្យវិស័យមីក្រូហិរញ្ញវត្ថុទទួលបានជោគជ័យ ក្នុងការផ្តល់សេវាដល់ប្រជាជនរាប់លានអ្នកដែលត្រូវការសេវានេះនៅកម្ពុជា និងសេដ្ឋកិច្ចដែលទើបតែងើបចេញពីការអភិវឌ្ឍឯទៀត ស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវតែប្រតិបត្តិការ នៅក្នុងទំរង់ដែលមាននិរន្តរភាពតាមបែបពាណិជ្ជកម្ម។ លទ្ធផលនៃការស្រាវជ្រាវ និងការអនុវត្តដែលតាមដានដោយក្រុមពិគ្រោះយោបល់ដើម្បីជួយដល់ជនក្រីក្របំផុត (Consultative Group to Assist the Poorest) បង្ហាញថា ការកំណត់អត្រាការប្រាក់ឱ្យនៅក្រោមថ្លៃចំនាយពិតប្រាកដនៃការឱ្យកំចី ឬការឧបត្ថម្ភធនលើមីក្រូហិរញ្ញវត្ថុដោយរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬម្ចាស់ជំនួយ ជាការមិនបានផល។ ការស្រាវជ្រាវបង្ហាញថា ជាញឹកញាប់ អ្នកទទួលផលមិនមែនជាអ្នកដែលត្រូវការមីក្រូហិរញ្ញវត្ថុជាចាំបាច់ទេ។ ពួកគេគឺជាសាច់ញាតិ និងមិត្តភក្តិរបស់អ្នកផ្តល់មីក្រូហិរញ្ញវត្ថុ។

យើងនៅក្នុងសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ មានមោទនភាពខ្លាំងណាស់ដែលបានចូលរួមចំណែកនៅក្នុងជោគជ័យរបស់ អ្នក។ ដោយចាប់ផ្តើមពីឆ្នាំ ១៩៩៩ ជា អ្នកប្រឹក្សាយោបល់របស់ ACLEDA និងក្រោយមកជាអ្នកវិនិយោគ និងអ្នកផ្តល់ប្រាក់កំចីដល់ ACLEDA យើងរួមជាមួយស្ថាប័នផ្សេងទៀតបានជួយឱ្យ ACLEDA វិវត្តទៅជាធនាគារពាណិជ្ជកម្មដែលនៅតែបន្តបំរើប្រជាជនក្រីក្រនៅជនបទកម្ពុជា។

ពួកយើងក៏បានជួយបង្កើត និងផ្តល់ហិរញ្ញវត្ថុក្នុងដំណាក់កាលដំបូង ដល់សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា ហើយធ្វើការងារលើបញ្ហាបទប្បញ្ញត្តិនានាចាប់ពីពេលនោះមក ដើម្បីជួយដល់ឧស្សាហកម្មនេះ។ ការងារទាំងនេះរួមមាន ការផ្តល់យោបល់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើច្បាប់ស្តីអំពីភារៈគ្រប់គ្រង (Trust Law) ដែលជួយឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុដែលកាន់កាប់ដោយអង្គការមិនមែនរដ្ឋាភិបាល អាចបង្កើតជាភារៈគ្រប់គ្រងឯករាជ្យ ដែលរដ្ឋាភិបាលទាមទារឱ្យអង្គការមិនមែនរដ្ឋាភិបាលកាត់ផ្តាច់នូវរាល់អាជីវកម្មដែលខ្លួនកាន់កាប់។ យើងក៏កំពុងតែធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើផ្នែកបទប្បញ្ញត្តិផ្សេងៗ ដើម្បីអនុញ្ញាតឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុនានាលក់ការធានារ៉ាប់រងខ្នាតតូច ព្រោះថា ជនក្រីក្រក៏ដូចជាមនុស្សគ្រប់គ្នាដែរត្រូវការធានាខ្លួនគេទល់នឹងហានិភ័យផ្សេងៗ ដែលអាចបោសសំអាតហិរញ្ញវត្ថុគ្រួសារទាំងស្រុង។ ជាមួយគ្នានេះដែរ យើងកំពុងតែធ្វើការជាមួយនឹងធនាគារជាតិនៃកម្ពុជា ក្នុងការកែលំអការចែករំលែកព័ត៌មានឥណទាន ដើម្បីឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុនានាដឹងថា ពេលណាដែលអ្នកខ្ចីមានប្រវត្តិឥណទានមិនល្អ ឬជំពាក់បំណុលច្រើន។ និងជាការពិតណាស់ យើងបានជួយឧបត្ថម្ភសន្និសិទកំពូលនេះម្តងរួចមកហើយកាលពីពីរឆ្នាំមុន។

ដូចដែលសហការីរបស់យើងនឹងជំរាបជូនលោកអ្នកក្នុងពេលបន្តិចទៀតនេះ ជំនួយឧបត្ថម្ភចុងក្រោយរបស់យើងលើវិស័យមីក្រូហិរញ្ញវត្ថុគឺ មូលនិធិដែលមានតំលៃ ៥00 លានដុល្លា ដែលសហការឧបត្ថម្ភដោយសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍របស់រដ្ឋាភិបាលអាឡឺម៉ង់KfW ដើម្បីជួយស្ថាប័នមីក្រូហិរញ្ញវត្ថុនានាឱ្យទទួលបាននូវហិរញ្ញវត្ថុដែលគេត្រូវការប្រសិនបើអ្នកឱ្យកំចីអន្តរជាតិជាទំលាប់កាត់បន្ថយហិរញ្ញវត្ថុរបស់គេ។ ហើយយើងក៏កំពុងតែបន្តផ្តល់យោបល់ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនទៀត ដូចជា AMK លើការកែលំអប្រតិបត្តិការ និងការបង្កើតសេវាសន្សំប្រាក់ និងផលិតផលថ្មីៗផ្សេងទៀត។

ដោយសារយើងបានឃើញថាផលប៉ះពាល់នៃវិបត្តិបានមកដល់កម្ពុជា សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិនឹងនៅប្រចាំការទីនេះដើម្បីជួយដល់លោកអ្នក។ វេទិកានេះផ្តល់នូវឱកាសដំបូង និងសំខាន់បំផុតមួយ ដើម្បីពិនិត្យមើលឡើងវិញពីកំរិតស្តង់ដារបច្ចុប្បន្នរបស់វិស័យមីក្រូហិរញ្ញវត្ថុ ទំរង់ផលប៉ះពាល់នៃវិបត្តិមកលើលោកអ្នករហូតមកដល់ពេលនេះ និងដែលអាចមាននៅថ្ងៃខាងមុខ។ ដោយមើលឃើញពីកំរិតកើនឡើងនៃប្រាក់កំចីពិបាកទារដែលឧស្សាហកម្មនេះកំពុងតែប្រឈមមុខ ថ្ងៃទីពីរនឹងផ្តោតទៅលើការអនុវត្តនានាលើការប្រមូល និងការឱ្យកំចីប្រកបដោយការទទួលខុសត្រូវ។ ចំនុចនេះគួរតែចាប់ផ្តើមការងាររបស់ពួកយើងជាមួយអ្នកទាំងអស់គ្នា លើការគ្រប់គ្រងហានិភ័យ និងការដោះស្រាយលើទ្រព្យសម្បត្តិក្នុងពេលមានវិបត្តិ។

ជាចុងក្រោយ ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នាឱ្យមានជោគជ័យក្នុងការពិភាក្សាក្នុងថ្ងៃនេះ និងថ្ងៃស្អែក ព្រមទាំងក្នុងការបន្តសំរេចបេសកកម្មរបស់អ្នកដើម្បីផ្តល់ដល់ជនក្រីក្រកម្ពុជានូវសេវា និងផលិតផលហិរញ្ញវត្ថុដែលមានតំលៃសមរម្យ និងចាត់ចែងប្រកបដោយសីលធម៌។